ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 08 / 05 / 2015
ម៉ោង (Time/Heure): 11:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Sann Rada

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# អង្គជំនុំជម្រះសាលាដំបូង

សាធារណៈ / Public

ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៥

**ជូនចំពោះ៖** **ភាគីទាំងអស់នៃសំណុំរឿង 002**

**ពី៖** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន៖** **លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ៖** **សេចក្តីសម្រេចអនុញ្ញាតឲ្យសាក្សីដែលមានរហស្សនាម 2-TCW-979 និង 2-TCW-822 ផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍**

១. កាលពីថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៥ អង្គជំនុំជម្រះបានជូនដំណឹងតាមអ៊ីមែលទៅកាន់ភាគីថា អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មរបស់សាក្សីដែលមានរហស្សនាម 2-TCW-979 និង 2-TCW-822 តាមរយៈប្រព័ន្ធសោតទស្សន៍ (ឧបសម្ព័ន្ធ ១)។ បន្ទាប់ពីមានការជំទាស់ពីមេធាវីការពារក្តី ខៀវ សំផន នៅក្នុងអំឡុងសវនាការកាលពីថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៥ ប្រធានអង្គជំនុំជម្រះបានពន្យល់ថា សាក្សីទាំងពីររូបនេះមិនអាចចូលរួមសវនាការដោយផ្ទាល់បានទេ ដោយសារតែបញ្ហាសុខភាពរបស់គាត់ (ប្រតិចារឹក ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៥ សេចក្តីព្រាង ទំព័រ ៤)។ នាពេលនេះ អង្គជំនុំជម្រះផ្តល់សំអាងហេតុបន្ថែមទៀតចំពោះសេចក្តីសម្រេចរបស់ខ្លួន ក្នុងការស្តាប់សក្ខីកម្មរបស់សាក្សីទាំងពីររូបតាមរយៈប្រព័ន្ធសោតទស្សន៍។

២. បន្ទាប់ពីមានសំណើសុំរបស់ការិយាល័យសហព្រះរាជអាជ្ញា (ឯកសារ E319/17) អង្គជំនុំជម្រះបានសម្រេចស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-979 (ឯកសារ E319/

17/1)។ បន្ទាប់ពីទទួលបានរបាយការណ៍ពីអង្គភាពគាំពារសាក្សី និង អ្នកជំនាញ ដែលបានលើកឡើងថា ស្ថានភាពសុខភាពសាក្សីរូបនេះធ្លាក់ចុះទ្រុឌទ្រោមយ៉ាងខ្លាំងដែលមិនអាចឱ្យគាត់ធ្វើដំណើរមកភ្នំពេញបានទេនោះ អង្គជំនុំជម្រះសាលាដំបូងបានស្នើឱ្យមានការវាយតម្លៃផ្នែកវេជ្ជសាស្ត្រដោយវេជ្ជបណ្ឌិតឯករាជ្យមួយរូបទៅលើសាក្សីរូបនេះ ដើម្បីកំណត់ថា តើគាត់អាចធ្វើដំណើរមកភ្នំពេញដើម្បីផ្តល់សក្ខីកម្មបានដែរ ឬ ទេ (ឯកសារ E29/470)។ របាយ-ការណ៍វេជ្ជសាស្ត្រដែលត្រូវបានរៀបចំដោយផ្អែកទៅលើការវាយតម្លៃនេះ បានសន្និដ្ឋានថា ផ្អែកលើស្ថានភាពជំងឺរបស់សាក្សី (ដែលរួមមាន ជំងឺលើសឈាមខ្ពស់ ជំងឺទឹកនោមផ្អែម និង ជំងឺរលាកសន្លាក់ឆ្អឹង) សាក្សីរូបនេះ មិនមានលទ្ធភាពធ្វើដំណើររាប់រយគីឡូម៉ែត្រមកទីក្រុងភ្នំពេញដើម្បីផ្តល់សក្ខីកម្មនៅ អ.វ.ត.ក ទេ (ឯកសារ E29/470/1 ទំព័រ ៦-៧) ហើយបានផ្តល់យោបល់ឱ្យផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍។

៣. នៅក្នុងកាលវិភាគដំបូង សាក្សីដែលមានរហស្សនាម 2-TCW-822 ត្រូវបានកំណត់ឱ្យមកផ្តល់សក្ខីកម្មនៅថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៥។ ប៉ុន្តែ ដោយសារតែស្ថានភាពជំងឺធ្ងន់ធ្ងរ គាត់ត្រូវសំរាកព្យាបាលនៅមន្ទីរពេទ្យនៅភ្នំពេញ ហើយមិនអាចផ្តល់សក្ខីកម្មបានឡើយ (សូមមើលប្រតិចារឹក ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៥ ទំព័រ ១៨-១៩)។ វេជ្ជបណ្ឌិតបានជូនដំណឹងមកអង្គភាពគាំពារសាក្សី និង អ្នកជំនាញ នៅពេលនោះ ថា សាក្សីរូបនេះមិនមានសម្បទាគ្រប់គ្រាន់ដើម្បីផ្តល់សក្ខីកម្មឡើយ និង ថា សាក្សីគួរត្រឡប់ទៅផ្ទះរបស់គាត់វិញដើម្បីបន្តការព្យាបាល។ ក្រោយមក អង្គភាពគាំពារសាក្សី និង អ្នកជំនាញ បានទៅជួបសាក្សី ហើយបានសន្និដ្ឋានថា ស្ថានភាពជំងឺរបស់គាត់កាន់តែដុនដាប ដោយសារតែគាត់មិនមានលទ្ធភាពទទួលការព្យាបាលតាមវេជ្ជបញ្ជា (ឧបសម្ព័ន្ធ ២)។

៤. អង្គជំនុំជម្រះសាលាដំបូងរម្លឹកថា អនុលោមតាមវិធាន ២៦ នៃវិធានផ្ទៃក្នុង សក្ខីកម្មរបស់សាក្សី ឬ អ្នកជំនាញក្នុងអំឡុងពេលជំនុំជម្រះ ត្រូវធ្វើឡើងដោយមានវត្តមានរបស់បុគ្គលនោះផ្ទាល់ នៅពេលណាដែលអាចធ្វើទៅបាន។ ប៉ុន្តែ ទោះបីយ៉ាងណាក៏ដោយ អង្គជំនុំជម្រះអាចអនុញ្ញាតឱ្យសាក្សីធ្វើសក្ខីកម្មតាមរយៈបច្ចេកវិទ្យាសោតទស្សន៍ ឬ ទូរទស្សន៍បាន ក្នុងករណីដែលបច្ចេកវិទ្យាបែបនេះអនុញ្ញាតឱ្យអង្គជំនុំជម្រះ និង ភាគី សាកសួរសាក្សីបាន នៅពេលដែលសាក្សីត្រូវឡើងផ្តល់សក្ខីកម្ម (វិធាន ២៦ (១) នៃផ្ទៃក្នុង)។

៥. អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិទូលំទូលាយក្នុងការសម្រេចទៅលើបញ្ហាថា តើត្រូវអនុញ្ញាតឱ្យផ្តល់សក្ខីកម្មតាមតាមរយៈប្រព័ន្ធសោតទស្សន៍ដែរ ឬ យ៉ាងណា។ ប្រសិនបើមាន

សំណើសុំវិធានការពិសេស អង្គជំនុំជម្រះត្រូវវាយតម្លៃអំពីសេចក្តីត្រូវការរបស់បុគ្គលដែលត្រូវផ្តល់សក្ខីកម្មនោះ។ អង្គជំនុំជម្រះបានសម្រេចថា ជាទូទៅ ការផ្តល់សក្ខីកម្មតាមតាមរយៈប្រព័ន្ធសោតទស្សន៍អាចត្រូវបានអនុញ្ញាតក្នុងកាលៈទេសៈដែលតម្រូវឱ្យធ្វើដូច្នេះ (ឯកសារ E166/1/4 ទំព័រ ១) ហើយកន្លងមក អង្គជំនុំជម្រះបានអនុញ្ញាតឱ្យមានការការផ្តល់សក្ខីកម្មតាមតាមរយៈប្រព័ន្ធសោតទស្សន៍ ក្នុងករណីដែលបញ្ហាសុខភាពធ្វើឱ្យសាក្សីមិនមានលទ្ធភាពធ្វើដំណើរមកផ្តល់សក្ខីកម្មដោយផ្ទាល់ (ឯកសារ E334 E1/151 និង E236/1/4/3)។

៦. ដោយពិនិត្យទៅលើស្ថានភាពសុខភាពរបស់សាក្សីទាំងពីររូបនេះ អង្គជំនុំជម្រះយល់ឃើញថា ការស្តាប់សក្ខីកម្មសាក្សីរបស់ពួកគាត់តាមរយៈប្រព័ន្ធសោតទស្សន៍ គឺជាការសមស្រប។ អង្គជំនុំជម្រះសាលាដំបូងក៏យល់ឃើញដែរថា ការប្រើប្រាស់ប្រព័ន្ធសោតទស្សន៍នៅក្នុងកាលៈទេសៈទាំងនេះមិនធ្វើឱ្យអន្តរាយធ្ងន់ធ្ងរ ឬ ប៉ះពាល់ទៅដល់សិទ្ធិការពារខ្លួនរបស់ជនជាប់ចោទឡើយ (សូមមើល វិធាន ២៦ (១) នៃផ្ទៃក្នុង)។